**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

## សេចក្ដីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្ដីពី
## ករណីវិជ្ជមានវីរុសកូវីដ ១៩ លើបុរសជនជាតិខ្មែរអាយុ ៣៨ ឆ្នាំ នៅខេត្តសៀមរាប

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនសាធារណជនទាំងអស់ ឲ្យបានជ្រាបថា បន្ទាប់ពីបានទទួលព័ត៌មានស្ដីពីករណីជនជាតិជប៉ុនអាយុជាង៤០ឆ្នាំ ម្នាក់ ដែលបានចាកចេញពីអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាបនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង០៨:៤៥នាទីយប់ ឆ្លងកាត់តាមព្រលានយន្តហោះទីក្រុងហូជីមិញ និងបានទៅដល់ប្រទេសជប៉ុននៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ ត្រូវបានរកឃើញនៅប្រទេសជប៉ុនថាមានវីរុសកូវីដ ១៩។ បុរសជនជាតិជប៉ុនរូបនេះ ជាធុរៈជន ធ្វើដំណើរច្រើនប្រទេស ដូចជាប្រទេសហ្វីលីពីន ឆ្លងកាត់ប្រទេសថៃ កម្ពុជា និងប្រទេសវៀតណាមផងដែរ។ ភ្លាមៗនោះ ក្រសួងបានចាត់វិធានការតាមរយៈមន្ទីរសុខាភិបាលខេត្តសៀមរាប ដោយមានការសហការពីអាជ្ញាធរខេត្ត ធ្វើការស្រាវជ្រាវរកអ្នកដែលប៉ះពាល់ទាំងផ្ទាល់និងប្រយោល ដែលជាលទ្ធផល គិតត្រឹមម៉ោង១២ថ្ងៃត្រង់នៃថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២០ យើងបានរកឃើញ ដូចតទៅ៖

- នៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០ បានរកឃើញអ្នកប៉ះពាល់ផ្ទាល់ជាមួយជនជាតិជប៉ុនមានវិជ្ជមានកូវីដ១៩ (Direct Contact) មានចំនួន ៤ នាក់ (ស្រី ២ និង ប្រុស ២ នាក់) មានអាយុចន្លោះពី ១៩ ទៅ ៣៨ ឆ្នាំ
- នៅព្រឹកថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២០ បានរកឃើញអ្នកប៉ះពាល់ផ្ទាល់ជាមួយជនជាតិជប៉ុនមានវិជ្ជមានកូវីដ ១៩ ជាស្ត្រីជនជាតិជប៉ុនចំនួន ០១ នាក់ និង ៣ នាក់ទៀត ដែលក្រុមគ្រួសារ របស់បុរសអាយុ ៣៨ ឆ្នាំ ខាងលើនេះ ដែលបច្ចុប្បន្ននេះ ក្រុមការងារនៃមន្ទីរសុខាភិបាលខេត្តសៀមរាបបាននាំពួកគាត់ឲ្យមកនៅបន្ទប់ដាច់ដោយឡែកនៃមន្ទីរពេទ្យបង្អែកខេត្តសៀមរាប
- អ្នកប៉ះពាល់ដោយប្រយោល (Indirect Contact) មានចំនួន ៤០ នាក់ (ស្រី ២៥ នាក់ និងប្រុស ១៥ នាក់) ដែលមានអាយុចន្លោះពី១៥ ដល់ ៤០ ឆ្នាំ។

អ្នកដែលប៉ះពាល់ផ្ទាល់ទាំង៤នាក់ នៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០ ត្រូវបានដាក់ឲ្យនៅបន្ទប់ដាច់ដោយឡែកនៃមន្ទីរពេទ្យខេត្តសៀមរាប។ ទោះជាពួកគាត់មិនមានចេញរោគសញ្ញាក៏ពិតមែន ឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល នៅល្ងាចម៉ោង៥ នៃថ្ងៃដដែល បានណែនាំឲ្យយកសំណាកវត្ថុវិភាគពីបុគ្គលទាំង៤នាក់នេះ ធ្វើវិភាគនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា។ រហូតមកដល់ម៉ោង ១២:៥០ នាទី នៃថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២០ ក្រសួងទទួលបានលទ្ធផលពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជាវិញថា **បុរសម្នាក់អាយុ៣៨ ឆ្នាំ** ដែលជាអ្នកប៉ះពាល់ផ្ទាល់ជាមួយបុរសជនជាតិជប៉ុនអាយុជាង៤០ឆ្នាំមានវីរុសកូវីដ១៩ នោះ **មានលទ្ធផលវិជ្ជមានវីរុសកូវីដ ១៩**។ រីឯ ៣ នាក់ (ស្រី ២ និង ប្រុស ១) ទៀត នោះ មានលទ្ធផលអវិជ្ជមានវីរុសកូវីដ១៩ នៅត្រឹមថ្ងៃដែលធ្វើតេស្ត ហើយក្រុមគ្រូពេទ្យនៃមន្ទីរសុខាភិបាលខេត្តសៀមរាប កំពុងតែបន្តតាមដានដោយយកចិត្តទុកដាក់បំផុតលើសុខភាពរបស់អ្នកទាំងអស់នេះ នៅក្នុងរយៈពេល១៤ថ្ងៃទៀត។

ដោយឡែកបុរសជនជាតិខ្មែរអាយុ ៣៨ ឆ្នាំ ដែលមានវិជ្ជមានកូវីដ ១៩ នោះ ត្រូវបានដាក់ឲ្យនៅដោយឡែកពីគេ ហើយបន្តការព្យាបាលដោយក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកខេត្តសៀមរាប ដោយយកចិត្តទុកដាក់ខ្ពស់ជាទីបំផុត។ អ្នកដែលប៉ះពាល់ផ្ទាល់រកឃើញចំនួន៤នាក់នៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២០ បន្ថែមទៀតនោះ ក៏ស្ថិតនៅក្រោមការតាមដានដោយហ្មត់ចត់ពីក្រុមគ្រូពេទ្យនៅខេត្តសៀមរាបនេះដែរ។

បច្ចុប្បន្ននេះ ក្រសួងសុខាភិបាលកម្ពុជា កំពុងបន្តតាមដានស្ថានភាពនៃជំងឺនេះនៅក្នុងប្រទេស ដោយមានការប្រឹក្សានិងសហការយ៉ាងជិតស្និទ្ធជាមួយអង្គការសុខភាពពិភពលោកប្រចាំនៅកម្ពុជា ហើយក្រសួងក៏សូមជម្រាបជូនសាធារណជនជ្រាបផងដែរថា ក្រុមការងារឆ្លើយតបបន្ទាន់ និងក្រុមគ្រូពេទ្យរបស់ក្រសួងសុខាភិបាល និងមន្ទីរសុខាភិបាលខេត្តសៀមរាប ដោយមានវត្តមានបុគ្គលិកអង្គការសុខភាពពិភពលោក និងមជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក បានទៅដល់ខេត្តសៀមរាបនៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០ ហើយកំពុងតែធ្វើការងារយ៉ាងសកម្មលើករណីចម្លងវីរុសកូវីដ ១៩ ខាងលើនេះ។ ក្រសួងកំពុងយកសំណាកវត្ថុវិភាគពីបុគ្គលទាំងអស់(ទាំងអ្នកប៉ះពាល់ផ្ទាល់និងមិនផ្ទាល់)ដើម្បីយកមកធ្វើតេស្តនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា។

ក្រសួងសុខាភិបាល សូមអំពាវនាវសារជាថ្មីម្តងទៀត សូមឲ្យលោកអ្នកធ្វើដំណើរដែលចេញទៅ ឬ វិលត្រឡប់មកពីតំបន់ ឬប្រទេសដែលមានការចម្លងនូវវីរុសកូវីដ ១៩ នេះ ត្រូវមានការប្រុងប្រយ័ត្នខ្ពស់បំផុត ដោយត្រូវចេះថែរក្សាសុខភាពផ្ទាល់ខ្លួន ដោយអនុវត្តនូវវិធានការណ៍សាមញ្ញៗមានដូចខាងក្រោមនេះ។ ប្រសិនបើលោកអ្នក មានរោគសញ្ញាដូចជា គ្រុនក្តៅ ក្អក និងពិបាកដកដង្ហើម ទាំងក្នុងអំឡុងពេល ធ្វើដំណើរ ឬបន្ទាប់ពីការវិលត្រឡប់មកពីកន្លែងដែលបានជម្រាបខាងលើ សូមទៅជួបវេជ្ជបណ្ឌិត (នៅមន្ទីរពេទ្យរដ្ឋដែលនៅជិតបំផុត) ភ្លាមនិងប្រាប់ពត៌មានដល់គ្រូពេទ្យអំពីប្រវត្តិនៃការធ្វើដំណើរ និងរោគសញ្ញារបស់លោកអ្នក។

**ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល មានប្រសាសន៍ថា៖ *ខ្ញុំសូមប្រកាសធ្វើការក្រើនរំលឹក ជូនដល់ប្រជាពលរដ្ឋទាំងអស់ ឲ្យមានការប្រុងប្រយ័ត្នខ្ពស់លើការបង្ការការចម្លងជំងឺរលាកសួតដោយវីរុសកូវីដ ១៩ នេះ ដោយអនុវត្តនូវវិធានការណ៍ដូចតទៅ៖*

១. ជៀសវាងប៉ះពាល់ជិតស្និទ្ធជាមួយអ្នកមានជំងឺផ្លូវដង្ហើមស្រួច ឬ អ្នកដែលមានបញ្ហាផ្លូវដង្ហើមសង្ស័យកូវីដ ១៩

២. លាងដៃឲ្យបានញឹកញាប់ (ជាមួយសាប៊ូ និងទឹកស្អាត) ជាពិសេសបន្ទាប់ពីប៉ះពាល់ដោយផ្ទាល់ជាមួយអ្នកជំងឺ ឬបរិស្ថានជុំវិញគាត់។

៣. អ្នកមានរោគសញ្ញាជំងឺផ្លូវដង្ហើមស្រួច ត្រូវខ្ទប់មាត់និងច្រមុះ នៅពេលក្អកឬកណ្តាស់ ដោយពាក់ម៉ាស់ ឬប្រើកន្សែង ឬក្រម៉ា ឬក្រដាសជូតមាត់ រួចបោះចោលឲ្យបានត្រឹមត្រូវ និងលាងដៃភ្លាមៗ។

៤. ត្រូវប្រកាន់យកនូវអនាម័យដៃស្អាត និងអនាម័យផ្លូវដង្ហើម (ខ្ទប់មាត់និងច្រមុះនៅពេលក្អកឬកណ្តាស់, លាងដៃបន្ទាប់ពីមានប៉ះជាមួយទឹករំអិលពីផ្លូវដកដង្ហើម និងរក្សាចម្ងាយច្រើនជាង១ម៉ែត្រ ពីបុគ្គលដែលមានរោគសញ្ញាផ្លូវដង្ហើមស្រួចស្រាវ ជាដើម)។

៥. ជៀសវាងប៉ះពាល់ជិតស្និទ្ធសត្វស្លាប់ ឬកសិដ្ឋានដែលមានសត្វរស់ ឬសត្វព្រៃ ឬកន្លែងដែលគេដឹងថាមានវីរុសកំពុងរាតត្បាត។ ចាំបាច់ ត្រូវលាងដៃឲ្យបានទៀងទាត់មុនពេល និងបន្ទាប់ពីការប៉ះពាល់សត្វ ឬវត្ថុផ្សេងៗ ដែលអាចជាប្រភពចម្លងរោគ។

៦. ប្រកាន់ខ្ជាប់នូវការអនុវត្តន៍អនាម័យស្អាត សុវត្ថិភាពម្ហូបអាហារល្អ និងពិសាអាហារដែលចំអិនឆ្អិនល្អ ។

ក្រសួងសុខាភិបាល និងបន្តធ្វើការជូនដំណឹងដល់សាធារណជន អំពីការវិវត្តន៍នៃបញ្ហាសុខភាពតាមគេហទំព័រ និងទំព័រហ្វេសបុករបស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសំភារៈអប់រំសុខភាពអំពីការបង្ការការឆ្លងជំងឺតាមផ្លូវដង្ហើម ដែលអាចទាញយកមកមើលបាន។

សំរាប់ព័ត៌មានបន្ថែម៖ សូមទាក់ទងលេខទូរស័ព្ទទាន់ហេតុការណ៍ដោយឥតគិតថ្លៃ 115 ទោះគ្មានថវិកាក្នុងទូរស័ព្ទរបស់អ្នកក៏អាចទូរស័ព្ទចូលបានដែរ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃសៅរ៍ ១៤ កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ពស ២៥៦៣

ភ្នំពេញ ថ្ងៃទី៧ ខែមីនា ឆ្នាំ២០២០



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩